ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
អគ្គនាយកដ្ឋានពន្ធដារ
លេខ ៧០១៥ អពដ

ថ្ងៃសុក្រ ៥រោច ខែកត្តិក ឆ្នាំកុរ ឯកស័ក ព.ស២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី ១៧ខែ មករា ឆ្នាំ២០២០

# សេចក្តីណែនាំ
## ស្តីពី
## ការអនុវត្តកាតព្វកិច្ចកាត់ទុកពន្ធលើអត្ថប្រយោជន៍បន្ថែមលើការផ្តល់ប្រាក់កម្ចីដល់និយោជិត

អនុលោមតាមបទប្បញ្ញត្តិនៃជំពូកទី៣ ផ្នែកទី៣.១ នៃប្រកាសលេខ ១១៧៣ សហវ.ពដ.ប្រក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៣ ស្តីពីពន្ធលើប្រាក់បៀវត្ស ការផ្តល់ប្រាក់កម្ចីដល់និយោជិតតាមអត្រាការប្រាក់ទាបជាងអត្រាការប្រាក់ទីផ្សារ គឺជាកម្មវត្ថុនៃពន្ធលើអត្ថប្រយោជន៍បន្ថែម ហើយអត្ថប្រយោជន៍បន្ថែម គឺត្រូវគិតលើលម្អៀងរវាងអត្រាការប្រាក់ដែលសហគ្រាសឱ្យនិយោជិតខ្ចី និងអត្រាការប្រាក់ទីផ្សារ។ ដូច្នេះ ក្នុងគោលបំណងពង្រឹងការអនុវត្តពន្ធលើអត្ថប្រយោជន៍បន្ថែមចំពោះការផ្តល់ប្រាក់កម្ចីដល់និយោជិត ឱ្យបានច្បាស់លាស់ និងមានសង្គតិភាព អគ្គនាយកដ្ឋានពន្ធដារសូមធ្វើការកំណត់អត្រាការប្រាក់ទីផ្សារ សម្រាប់ជាមូលដ្ឋានគិតពន្ធលើអត្ថប្រយោជន៍បន្ថែម ដូចខាងក្រោម÷

ក. អត្រាការប្រាក់អប្បបរមានៃកម្ចីដែលផ្តល់ជូនអតិថិជន ឬអ្នកជំពាក់បំណុលដទៃទៀត (ដែលមិនមែនជាបុគ្គលទាក់ទិន) ឬ

ខ. អត្រាការប្រាក់ទីផ្សារសម្រាប់ប្រាក់កម្ចីប្រចាំឆ្នាំ មុនឆ្នាំជាប់ពន្ធចរន្ត (N-1) ដែលកំណត់ដោយសេចក្តីជូនដំណឹងរបស់អគ្គនាយកដ្ឋានពន្ធដារ។

អគ្គនាយកដ្ឋានពន្ធដារសង្ឃឹមជឿជាក់យ៉ាងមុតមាំថា លោក-លោកស្រីជាម្ចាស់ និងជាបណ្ណាធិការ នៃសហគ្រាសទាំងអស់ នឹងយកចិត្តទុកដាក់អនុវត្តតាមខ្លឹមសារនៃសេចក្តីណែនាំនេះ បានយ៉ាងខ្ជាប់ខ្ជួន ប្រកបដោយតម្លាភាព និងស្មារតីទទួលខុសត្រូវ ព្រមទាំងកិច្ចសហការខ្ពស់។

ប្រតិភូរាជរដ្ឋាភិបាល
ទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធដារ

គង់ វិបុល